តើលោកអ្នកមានសិទ្ធិទទួលបានជំនួយផ្នែកហិរញ្ញវត្ថុឬទេ?

មែនហើយ ភាគច្រើននឹងទទួលបាន! ប្រហែល 90% នៃអ្នកចុះឈ្មោះរបស់ Covered California ទទួលបានជំនួយផ្នែកហិរញ្ញវត្ថុ។ ជំនួយផ្នែកហិរញ្ញវត្ថុបានប៉ុន្មានគឺអាស្រ័យលើប្រាក់ចំណូលគ្រួសារ ទំហំគ្រួសារ និងទីកន្លែងដែលអ្នករស់នៅ។

លោកអ្នកអាចបង់ប្រាក់តិចស្មើនឹង $0/ខែ សម្រាប់ផែនការរបស់លោកអ្នក ហើយលោកអ្នកនឹងមិនបង់ប្រាក់លើសពី 8.5% នៃប្រាក់ចំណូលរបស់លោកអ្នកសម្រាប់គម្រោង Silver មូលដ្ឋានរបស់យើងទេ។ លោកអ្នកក៏អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោង Medi-Cal ឥតថ្លៃទាប ឬមិនគិតថ្លៃផងដែរ។

ដើម្បីប៉ាន់ប្រមាណការបង់ប្រាក់ប្រចាំខែរបស់អ្នកដោយឧបករណ៍គណនារបស់យើង (ជាភាសាអង់គ្លេស) សូមស្កេនកូដ QR ឬចូលមើលគេហទំព័រ CoveredCA.com/#quick-calculator

តើខ្ញុំត្រូវមានការធានារ៉ាប់រងសុខភាពដែរឬទេ?

នៅរដ្ឋកាលីហ្វ័រញ៉ា មនុស្សភាគច្រើនត្រូវបានតម្រូវដោយច្បាប់ឲ្យមានការធានារ៉ាប់រងសុខភាព ឬមិនដូចនោះទេនឹងត្រូវបង់ពិន័យពន្ធ៖ $850/មនុស្សពេញវ័យ + $425/កុមារអាយុក្រោម 18 ឆ្នាំ, រហូតដល់ $2,550/គ្រួសារ ឬ 2.5% នៃប្រាក់ចំណូលប្រចាំឆ្នាំនៃគ្រួសាររបស់អ្នកលើកម្រិតដែលត្រូវប្រកាសពន្ធរបស់រដ្ឋកាលីហ្វ័រញ៉ា មួយណាដែលខ្ពស់ជាង។

មានសំណួរផ្សេងទៀតមែនទេ? សូមចូលមើលគេហទំព័រ CoveredCA.com/support

Covered California complies with applicable Federal civil rights laws and does not discriminate on the basis of race, color, national origin, age, disability, or sex.
Atención: si habla español, tiene a su disposición servicios gratuitos de asistencia lingüística. Llame al 1.800.300.0213 (TTY: 1.888.889.4500).
注意：如果您使用繁體中文，您可以免費獲得語言援助服務。請致電 1.800.300.1533 (TTY 1.888.889.4500).

ដែលលោកអ្នកត្រូវការដើម្បីចុះឈ្មោះ។

ឯកសារខាងក្រោម គឺជាឯកសារត្រូវការសម្រាប់សមាជិកគ្រួសារម្នាក់ៗដែលដាក់ពាក្យសុំការធានារ៉ាប់រង។

- **លេខហ្សីបកូដផ្ទះ**
- **ខែឆ្នាំកំណើត**
- **ភ័ស្តុតាងពីប្រាក់ចំណូលបច្ចុប្បន្នរបស់គ្រួសារ ***
- **អត្តសញ្ញាណប័ណ្ណរដ្ឋកាលីហ្វ័រញ៉ា ឬប័ណ្ណបើកបរ**
- **លេខសន្តិសុខសង្គម ឬលេខអត្តសញ្ញាណកម្មអ្នកបង់ពន្ធបុគ្គល បើអ្នកមាន**
- **ភស្តុតាងនៃភាពជាពលរដ្ឋ ឬវត្តមានស្របច្បាប់ (ឧ. លិខិតឆ្លងដែន សហរដ្ឋអាមេរិក វិញ្ញាបនប័ត្រពលរដ្ឋ ឬឯកសារចូលសញ្ជាតិ បណ្ណសិទ្ធរស់នៅអចិន្ត្រៃយ៍ ឬទិដ្ឋាការដែលមានសុពលភាព) * ***

សម្រាប់ព័ត៌មានបន្ថែម និងជំនួយដោយផ្ទាល់ដោយឥតគិតថ្លៃ សូមទាក់ទង៖

CoveredCA.com | 800.906.8528 (ខ្មែរ)

*ភ័ស្តុតាងនៃប្រាក់ចំណូលបច្ចុប្បន្នរបស់សមាជិកទាំងអស់នៅក្នុងគ្រួសារអ្នកជាប់ពន្ធ ដូចជាលិខិតប្រកាសពន្ធនាពេលថ្មីៗ ទម្រង់ W-2 ឬបង្កាន់ដៃបើកប្រាក់ខែ។ ប្រាក់ចំណូលរបស់មនុស្សនៅក្នុងបន្ទុកគួរតែដាក់បញ្ចូលតែក្នុងករណីដែលកម្រិតប្រាក់ចំណូលរបស់ពួកគេតម្រូវឱ្យពួកគេដាក់លិខិតប្រកាសពន្ធតែប៉ុណ្ណោះ។ គ្រួសារត្រូវបានឱ្យនិយមន័យថា ជាបុគ្គលដែលដាក់លិខិតប្រកាសពន្ធក្នុងនាមជាអ្នកដាក់លិខិតប្រកាសពន្ធបឋម ហើយមនុស្សនៅក្នុងបន្ទុកទាំងអស់ត្រូវបានប្រកាសផ្នែកលើពន្ធរបស់បុគ្គលនោះ។ ប្រសិនបើលោកអ្នកមិនដាក់លិខិតប្រកាសពន្ធទេ លោកអ្នកនៅតែអាចមានលក្ខណៈសម្បត្តិទទួលបានការធានារ៉ាប់រងដោយឥតគិតថ្លៃ ឬតម្លៃទាបតាមរយៈ Medi-Cal។
**លោកអ្នកអាចដាក់ពាក្យសុំសម្រាប់កូន ឬប្តី/ប្រពន្ធដែលមានសិទ្ធិទទួលរបស់លោកអ្នក ទោះបីជាលោកអ្នកមិនមានសិទ្ធិទទួលក៏ដោយ។

KHM-0723

វិធីនេះទៅកាន់ការធានារ៉ាប់រងសុខភាព។

ពេលវេលា ទីកន្លែង និងរបៀបចុះឈ្មោះ

COVERED CALIFORNIA

COVERED CALIFORNIA

យើងជួយឲ្យលោកអ្នកទទួលបានការធានារ៉ាប់រង។

Covered California ត្រូវបានបង្កើតឡើងដើម្បីជួយឲ្យអ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ាអាចប្រៀបធៀប មានលទ្ធភាពទិញ និងចុះឈ្មោះក្នុងបណ្តាគម្រោងធានារ៉ាប់រងសុខភាពដែលល្អៗ។ មនុស្សភាគច្រើនដែលចុះឈ្មោះគឺទទួលបានជំនួយផ្នែកហិរញ្ញវត្ថុ ហើយមនុស្សគ្រប់រូបត្រូវបានធានាថាទទួលបានការធានារ៉ាប់រងដែលមានគុណភាពខ្ពស់ដូចគ្នា។

យើងនៅទីនេះដើម្បីជួយ។

Covered California ផ្តល់ជូននូវជំនួយដែលមានជំនាញ ដោយឥតគិតថ្លៃ តាមអនឡាញ ដោយផ្ទាល់ និងតាមទូរសព្ទ ដែលមាន 13 ភាសា ក៏ដូចជាសម្រាប់មនុស្សដែលស្តាប់មិនសូវឮផងដែរ។

ការចុះឈ្មោះបើកនៅថ្ងៃទី

ថ្ងៃទី 1 ខែវិច្ឆិកា - ថ្ងៃទី 31 ខែមករា

Medi-Cal និងការចុះឈ្មោះពិសេសគឺមានពេញមួយឆ្នាំ។ ការចុះឈ្មោះពិសេសអនុញ្ញាតឱ្យអ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ាទទួលបានការធានារ៉ាប់រងក្នុងរយៈពេល 60 ថ្ងៃនៃព្រឹត្តិការណ៍ជីវិតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន ដូចជាការបាត់បង់ធានារ៉ាប់រងសុខភាព ការផ្លាស់ប្តូរទំហំគ្រួសារ ឬការផ្លាស់ទីលំនៅទៅ ឬនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។ សម្រាប់ពត៌មានបន្ថែម សូមចូលមើលគេហទំព័រ **CoveredCA.com/special-enrollment**។

ដើម្បីចាប់ផ្តើម
សូមចូលមើលគេហទំព័រ CoveredCA.com
ឬទូរសព្ទទៅលេខ 800.906.8528 (ខ្មែរ)។

ស្រាវជ្រាវរកមើលជម្រើសនៃការធានារ៉ាប់រងរបស់លោកអ្នក។

Covered California ផ្តល់ការធានារ៉ាប់រងបួនកម្រិត៖ Bronze, Silver, Gold និង Platinum។ ក្រុមហ៊ុនធានារ៉ាប់រងសុខភាពបង់ប្រាក់មួយចំណែកសម្រាប់សេវាកម្មដែលត្រូវបានធានារ៉ាប់រង ហើយអត្ថប្រយោជន៍ដែលបានផ្តល់ជូនក្នុងកម្រិតនីមួយៗមានលក្ខណៈដូចគ្នា មិនថាលោកអ្នកជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងណាឡើយ។

សូមចូលមើលគេហទំព័រ CoveredCA.com ហើយជ្រើសរើស “Shop and Compare” ដើម្បីពិនិត្យមើលថាតើគម្រោងធានារ៉ាប់រងសុខភាពល្អៗណាខ្លះដែលស័ក្តិសមនឹងលោកអ្នក។

ជ្រើសរើសគម្រោង **Platinum** ឬ **Gold** លោកអ្នកនឹងបង់ថ្លៃបុព្វលាភប្រចាំខែខ្ពស់ជាង ប៉ុន្តែលោកអ្នកនឹងចំណាយតិចជាងលើសេវាកម្មវេជ្ជសាស្ត្រនៅពេលដែលលោកអ្នកត្រូវការពួកវា។

ជ្រើសរើសគម្រោង **Silver** ឬ **Bronze** លោកអ្នកនឹងបង់ថ្លៃបុព្វលាភប្រចាំខែទាបជាង ប៉ុន្តែលោកអ្នកនឹងចំណាយច្រើនជាងលើសេវាកម្មវេជ្ជសាស្ត្រនៅពេលដែលលោកអ្នកត្រូវការពួកវា។

គម្រោងធានារ៉ាប់រងអប្បបរមាគឺអាចរកបានសម្រាប់អ្នកដែលមានអាយុក្រោម 30 ឆ្នាំ ឬអ្នកដែលមានអាយុចាប់ពី 30 ឆ្នាំឡើងទៅដែលទទួលការលើកលែងសម្រាប់អ្នកជួបការលំបាក។

អត្ថប្រយោជន៍នៃការធានារ៉ាប់រងស្តង់ដារតាមកម្រិត –

អត្ថប្រយោជន៍សំខាន់ៗ	BRONZE ធានារ៉ាប់រងលើ 60% នៃចំណាយប្រចាំឆ្នាំជាមធ្យម	SILVER ធានារ៉ាប់រងលើ 70% នៃចំណាយប្រចាំឆ្នាំជាមធ្យម	GOLD ធានារ៉ាប់រងលើ 80% នៃចំណាយប្រចាំឆ្នាំជាមធ្យម	PLANTUM ធានារ៉ាប់រងលើ 90% នៃចំណាយប្រចាំឆ្នាំជាមធ្យម
តម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យជាលក្ខណៈបុគ្គល/គ្រួសារ	$6,300 / $12,600	$5,400 / $10,800**	គ្មានតម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យទេ	គ្មានតម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យទេ
ការទៅពិនិត្យសុខភាពប្រចាំឆ្នាំដើម្បីបង្ការជំងឺ	គ្មានចំណាយ	គ្មានចំណាយ	គ្មានចំណាយ	គ្មានចំណាយ
តម្លៃត្រូវបង់ពេលទៅពេទ្យម្តងៗសម្រាប់ការពិនិត្យសុខភាពបឋម	$60*	$50	$35	$15
តម្លៃត្រូវបង់ពេលទៅពេទ្យម្តងៗសម្រាប់ការថែទាំសុខភាពបន្ទាន់	$60*	$50	$35	$15
តម្លៃត្រូវបង់ពេលទៅពេទ្យម្តងៗសម្រាប់បន្ទប់សង្គ្រោះបន្ទាន់	40%†	$450	$350	$150
តម្លៃត្រូវបង់ពេលទៅពេទ្យម្តងៗសម្រាប់ថ្នាំទូទៅ	$17	$19	$15	$7
ចំណាយពីហោប៉ៅអតិបរមាប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់	$9,100	$9,100	$8,700	$4,500
ចំណាយពីហោប៉ៅអតិបរមាប្រចាំឆ្នាំសម្រាប់គ្រួសារ**	$18,200	$18,200	$17,400	$9,000

តារាងមិនរួមបញ្ចូលអត្រាទាំងអស់នៃសហធានារ៉ាប់រង និងតម្លៃត្រូវបង់ពេលទៅពេទ្យម្តងៗទេ។ សម្រាប់ព័ត៌មានពេញលេញ សូមចូលមើលគេហទំព័រ CoveredCA.com។
*សម្រាប់គម្រោង Bronze តម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យត្រូវបានលើកលែងសម្រាប់ការពិនិត្យថែទាំសុខភាពបឋម ឬបន្ទាន់ចំនួនបីលើកដំបូង។ ការទៅពិនិត្យបន្ថែមនឹងត្រូវបានគិតកម្រៃពេញរហូតដល់គ្រប់ចំនួនតម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ។
**គម្រោង Silver គឺជាកម្រិតគម្រោងតែមួយគត់ដែលតម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យរបស់លោកអ្នក និងចំណាយផ្សេងទៀតអាចមានចំនួនទាបជាង ផ្អែកលើប្រាក់ចំណូលគ្រួសាររបស់លោកអ្នក។
†40% បន្ទាប់ពីតម្លៃត្រូវបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ រហូតដល់ចំណាយពីហោប៉ៅអតិបរមាប្រចាំឆ្នាំ។